**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**

លេខ:......០០៣/១៥.........គ.ម.ក/ប្រ.ក.

# ប្រកាស

# ស្តីពី

# ការដាក់ឱ្យអនុវត្តនូវការកែប្រែ

# វិធានប្រតិបត្តិការរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គមក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99 Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh

- បានឃើញប្រកាសលេខ ០០៤ គមក.ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្ដីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០២/១១គ.ម.ក ប្រ.ក.ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្ដីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការរក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៥/១១គ.ម.កប្រ.ក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្ដីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការជាត់ទាត់ និងទូទាត់មូលបត្រ
- បានឃើញប្រកាសលេខ ០០៦/១១គ.ម.កប្រ.ក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្ដីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រ
- បានឃើញប្រកាសលេខ ០០១/១២ស្ន២ គ.ម.ក/ប្រ.ក. ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ស្ដីពីការដាក់ឱ្យអនុវត្តនូវការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការជាត់ទាត់ និងទូទាត់មូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- បានឃើញប្រកាសលេខ ០០១/១២ស្ន៣ គ.ម.ក/ប្រ.ក. ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ស្ដីពីការដាក់ឱ្យអនុវត្តនូវការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- បានឃើញប្រកាសលេខ ០០១/១២ស្ន៤ គ.ម.ក/ប្រ.ក. ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ស្ដីពីការដាក់ឱ្យអនុវត្តនូវការកែប្រែថ្លៃសេវា ក្នុងវិធានប្រតិបត្តិការរក្សាទុកមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- បានឃើញប្រកាសលេខ ០០១/១៣ គ.ម.ក/ប្រ.ក. ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣ ស្ដីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- បានឃើញប្រកាសលេខ ០០១/១៤ គ.ម.ក/ប្រ.ក. ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ ស្ដីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- យោងតាមសំណើសុំបន្ថយបញ្ចុះថ្លៃសេវាប្រតិបត្តិការជួញដូរមូលបត្រ ថ្លៃសេវាជាត់ទាត់ និងទូទាត់មូលបត្រ និងថ្លៃសេវាផ្ទេរមូលបត្ររវាងគណនីនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៤
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា លើកទី៣៥ នាថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥។

# ស ម្រេ ច

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តនូវប្រការ ២៤ ថ្មី (បី) នៃវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ជំនួសប្រការ ២៤ថ្មី (ពីរ) នៃវិធានប្រតិបត្តិការទីផ្សារមូលបត្រ

ដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ០០១/១៤ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**ប្រការ ២.-**

ដាក់ឱ្យអនុវត្តនូវប្រការ ១៤ ថ្មី (បី) នៃវិធានប្រតិបត្តិការជាត់ទាត់និងទូទាត់មូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ជំនួសប្រការ ១៤ថ្មី (ពីរ) នៃវិធានប្រតិបត្តិការជាត់ទាត់និងទូទាត់មូលបត្រ ដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ០០១/១៤ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**ប្រការ ៣.-**

ដាក់ឱ្យអនុវត្តនូវប្រការ ១៣ ថ្មី (បី) នៃវិធានប្រតិបត្តិការរក្សាទុកមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ជំនួសប្រការ ១៣ថ្មី (ពីរ) នៃវិធានប្រតិបត្តិការរក្សាទុកមូលបត្រ ដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ០០១/១៤ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**ប្រការ ៤.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀត ចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០១៥

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- ដូចប្រការ៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

**ឧបសម្ព័ន្ធប្រកាសលេខ ០០៣/១៥**

**ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ ២០១៥**

**ស្តីពី**

**ការកែប្រែវិធានប្រតិបត្តិការទីផ្សារមូលបត្រ**

**របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

* * * * *

**ប្រការ ២៤ ថ្មី (បី).- ថ្លៃសេវាជួញដូរមូលបត្រ**

សមាជិកត្រូវបង់ថ្លៃសេវាប្រតិបត្តិការពាក់ព័ន្ធនឹងសេវាដែលបានផ្តល់ឱ្យស្របតាមវិធាននេះ។

របៀបគណនាថ្លៃសេវាជួញដូរ អ្នកបង់ប្រាក់ និងពេលវេលាបង់ប្រាក់ ត្រូវបានកំណត់ដូចខាងក្រោម÷

១-អត្រាថ្លៃសេវាសម្រាប់ជួញដូរមូលបត្រកម្មសិទ្ធិ ត្រូវគណនាលើទឹកប្រាក់នៃការជួញដូរ ដែលបានទូទាត់ (ថ្លៃសេវាដែលគណនាត្រូវកាត់យកមួយខ្ទង់ក្រោយក្បៀស) តាមអត្រា ១៥/១០.០០០ (ដប់ប្រាំភាគមួយម៉ឺន) ឬ ០,១៥ % (សូន្យក្បៀសដប់ប្រាំភាគរយ)។

២-អ្នកត្រូវបង់ថ្លៃសេវា គឺក្រុមហ៊ុនមូលបត្រដែលជាសមាជិករបស់ ផ.ម.ក.។

៣-ពេលវេលាបង់ថ្លៃសេវា គឺម៉ោង ៨:៣០ ព្រឹក នៃកាលបរិច្ឆេទទូទាត់។

សម្រាប់ឆ្នាំ ២០១៥ ថ្លៃសេវាសម្រាប់សេវាជួញដូរមូលបត្រកម្មសិទ្ធិ ដូចមានចែងក្នុងកថាខណ្ឌទី២ ចំនុចទី១ ខាងលើត្រូវកាត់បន្ថយចំនួន ៥០% មកត្រឹមអត្រា ៧,៥/១០.០០០ (ប្រាំពីរក្បៀសប្រាំភាគមួយម៉ឺន) ឬ ០,០៧៥% (សូន្យក្បៀសសូន្យចិតសិបប្រាំ ភាគរយ)។

## ឧបសម្ព័ន្ធប្រកាសលេខ.០០៣/១៥

## ចុះថ្ងៃទី០៧ខែមេសា ឆ្នាំ ២០១៥

## ស្ដីពី

## ការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

**ប្រការ ១៤ ថ្មី (ចី).- ថ្លៃសេវាផាត់ទាត់និងទូទាត់មូលបត្រ**

សមាជិកត្រូវបង់ថ្លៃសេវាផាត់ទាត់និងទូទាត់ ជូនប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ តាមអត្រា និងពេលវេលាដូចខាងក្រោម÷

១-ថ្លៃសេវាសម្រាប់សេវាផាត់ទាត់និងទូទាត់មូលបត្រ ត្រូវយកលើតម្លៃជួញដូរដែលត្រូវបានទូទាត់ (ថ្លៃសេវាត្រូវកាត់កៀសមកត្រឹមមួយខ្ទង់) តាមអត្រា ៥/១០.០០០ (ប្រាំភាគមួយម៉ឺន) ឬ ០,០៥% (សូន្យក្បៀសសូន្យប្រាំភាគរយ)។

២-អ្នកបង់ថ្លៃសេវា គឺក្រុមហ៊ុនមូលបត្រដែលជាសមាជិកនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ។

៣-ពេលវេលានៃការបង់ថ្លៃសេវា គឺនៅម៉ោង ៨:៣០ ព្រឹក នៃកាលបរិច្ឆេទទូទាត់។

សម្រាប់ឆ្នាំ ២០១៥ ថ្លៃសេវាសម្រាប់ផាត់ទាត់និងទូទាត់មូលបត្រ ដូចមានចែងក្នុងកថាខណ្ឌទី១ ចំនុចទី១ ខាងលើ ត្រូវកាត់បន្ថយចំនួន ៥០% មកត្រឹមអត្រា ២,៥/១០.០០០ (ពីរក្បៀសប្រាំភាគមួយម៉ឺន) ឬ ០,០២៥% (សូន្យក្បៀសសូន្យម្ភៃប្រាំភាគរយ)។

**ឧបសម្ព័ន្ធប្រកាសលេខ.០០៣./១៥**

**ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៥**

**ស្ដីពី**

**ការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការរក្សាទុកមូលបត្រ**

**របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

* * * * *

**ប្រការ ១៣ ថ្មី (បី).-ថ្លៃសេវាប្រតិបត្តិការរក្សាទុកមូលបត្រ**

សមាជិក និងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ត្រូវបង់ថ្លៃសេវារក្សាទុកមូលបត្រ ថ្លៃសេវាផ្ទេរមូលបត្ររវាងគណនី និងថ្លៃសេវាផ្សេងទៀត សម្រាប់សេវាដែលបានទទួលស្របតាមប្រការនេះ។

សមាជិក និងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ត្រូវបង់ថ្លៃសេវាជូន ផ.ម.ក. ដូចខាងក្រោម÷

១- ថ្លៃសេវារក្សាទុកមូលបត្រ÷ ជាថ្លៃសម្រាប់ការដាក់ផ្ញើមូលបត្រ ដែលស្ថិតក្នុងនីតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ (IPO)។ ថ្លៃសេវារក្សាទុកមូលបត្រប្រចាំខែ ត្រូវបង់នៅថ្ងៃទី១០នៃខែបន្ទាប់ពីខែដែលថ្លៃសេវានោះបានកើតឡើង និងត្រូវបង់តាមលក្ខខណ្ឌដូចខាងក្រោម÷

ក- អត្រា ២០ (ម្ភៃ) រៀល លើមូលដ្ឋាននៃទឹកប្រាក់ ១០.០០០.០០០ (ដប់លាន) រៀល។ ក្នុងករណីនេះ ថ្លៃសេវា ត្រូវកំណត់យកលើមូលដ្ឋានសមតុល្យប្រចាំថ្ងៃ ដែលបង្ហាញជូននៅក្នុងសៀវភៅគណនីមូលបត្រ។ ថ្លៃសេវានេះ មិនត្រូវលើសពី ១២០.០០០ (មួយរយម្ភៃពាន់) រៀល ក្នុងមួយថ្ងៃឡើយ។

ខ- អ្នកត្រូវបង់ថ្លៃសេវា គឺជាក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ។

២- ថ្លៃសេវាផ្ទេរមូលបត្ររវាងគណនី (Book Entry Fee)÷

ក- អត្រាថ្លៃសេវានៃការផ្ទេរមូលបត្ររវាងគណនី ត្រូវគណនាលើមូលដ្ឋានទឹកប្រាក់នៃការជួញដូរ ដែលបានទូទាត់តាមអត្រា១០/១០.០០០(ដប់ភាគមួយម៉ឺន) ឬ ០,១០% (សូន្យក្បៀសដប់ភាគរយ) ចំពោះមូលបត្រកម្មសិទ្ធិ ហើយថ្លៃសេវាត្រូវកាត់យកមួយខ្ទង់ក្រោយក្បៀស។

ខ- អ្នកត្រូវបង់ថ្លៃសេវា គឺជាក្រុមហ៊ុនមូលបត្រដែលជាសមាជិក។

គ- ពេលវេលាបង់ថ្លៃសេវា គឺនៅម៉ោង ៨:៣០ ព្រឹក នៃកាលបរិច្ឆេទទូទាត់។

៣- ថ្លៃសេវាប្រតិបត្តិការផ្សេងៗ÷

ក- ថ្លៃសេវានៃការផ្ទេរមូលបត្រ ដែលមិនត្រូវបានជួញដូរគឺ ១០០.០០០ (មួយរយពាន់) រៀលក្នុងមួយប្រតិបត្តិការ។ សមាជិក និងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ត្រូវបង់ថ្លៃសេវានេះជូនប្រតិបត្តិកររក្សាទុកមូលបត្រនៃ ផ.ម.ក. នៅពេលស្នើសុំផ្ទេរមូលបត្រ។

ខ- ថ្លៃសេវានៃការដកមូលបត្រគឺ ២០០.០០០(ពីររយពាន់)រៀលក្នុងមួយប្រតិបត្តិការ។ សមាជិក និង ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ត្រូវបង់ថ្លៃសេវានេះជូនប្រតិបត្តិកររក្សាទុកមូលបត្រនៃ ផ.ម.ក. នៅពេលស្នើសុំដកមូលបត្រ។

សម្រាប់ឆ្នាំ២០១៥ អត្រាថ្លៃសេវានៃការផ្ទេរមូលបត្ររវាងគណនី ដូចមានចែងក្នុងកថាខណ្ឌទី ២ ចំណុចទី ២ "ក" ខាងលើ ត្រូវកាត់បន្ថយចំនួន ៥០% មកត្រឹមអត្រា ៥/១០.០០០(ប្រាំភាគមួយម៉ឺន)ឬ0,0៥% (សូន្យក្បៀសសូន្យប្រាំភាគរយ)ចំពោះមូលបត្រកម្មសិទ្ធិ ហើយថ្លៃសេវាត្រូវកាត់យកមួយខ្ទង់ក្រោយក្បៀស។